# ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស : ទស្សនវិស័យនៃការធ្វើផែនការគ្រប់គ្រងដីធ្លី ដើម្បីធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន

DIEPART, Jean-Christophe (Spatial Planning advsior, German Development Service)
SEM Thol (Local Expert, German Development Service)

## ១. សេចក្តីផ្តើម

កាលពីទសវត្សរ៍មុន ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏មូលដ្ឋាន ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយចំពោះការចូលរួមចំណែកដល់ការអភិរក្សជីវចំរុះ និងសំរាប់ការរស់នៅចិញ្ចឹមជីវិតប្រកបដោយស្ថេរភាពនៅក្នុងប្រទេសកម្ពុជា (Ken Serei, 2005 )។ វាត្រូវបានទទួលនូវការចាប់អារម្មណ៍យ៉ាងខ្លាំងដោយចាត់ទុកថាវាជាវិធីសាស្ត្រមួយដែលជួយលើកស្ទួយដល់ការអភិវឌ្ឍន៏ជនបទប្រកបដោយចិរភាព។ ដោយសារតែមានការគាំទ្រយ៉ាងខ្លាំងខ្លាជាយុទ្ធសាស្ត្រពីអង្គការជាតិ និងអន្តរជាតិបានធ្វើអោយវិធីសាស្ត្រគ្រប់គ្រងដោយមានករចូលរួមពីសហគមន៏មូលដ្ឋាននេះក្លាយទៅជាវិធីសាស្ត្រមួយយ៉ាងសំខាន់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា។

ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏មូលដ្ឋាននេះ ត្រូវបានធ្វើការអនុវត្តន៏តាមរយៈវិធីសាស្ត្រដែលផ្តោតជាសំខាន់ទៅលើបរិបទនៅក្នុងមូលដ្ឋាន។ វាផ្តោតជាសំខាន់ទៅលើការគាំទ្រដល់សហគមន៏មូលដ្ឋានទៅលើការពង្រឹងអភិបាលកិច្ចមូលដ្ឋានជំរុញដល់ការធ្វើសេចក្តីសំរេចចិត្តនៅក្នុងថ្នាក់មូលដ្ឋាន ហើយនិងសម្របសម្រួលដល់ការអនុវត្តន៏ផែនការគ្រប់គ្រងធនធានធម្មជាតិដែលរៀបចំឡើងនៅក្នុងតំបន់មូលដ្ឋាន។
វិធីសាស្ត្រសំខាន់ ដែលគេប្រើជាទូទៅសំរាប់ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៏មូលដ្ឋាន ដែលបានអនុវត្តកន្លងមកគឺផ្តោតធ្ងន់ទៅលើបរិបទនៅមូលដ្ឋាន។ សំខាន់គឺប្រសិនបើមានការចូលរួមពីប្រជាជនមូលដ្ឋាន (ជាពិសេសប្រជាជនក្រីក្រ ស្ត្រី) ត្រូវបានធ្វើការសម្របសម្រួលនិងមានការគាំទ្រពីមូលដ្ឋានដល់គណៈកម្មការគ្រប់គ្រង ដើម្បីអោយពួកគេពង្រឹងសមត្ថភាពជំនាញរបស់ពួកគេក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ វានឹងធ្វើអោយមានភាពល្អប្រសើរដល់សុវត្ថិភាពកាន់កាប់ដីធ្លីនៅក្នុងសហគមន៏ ធ្វើអោយប្រសើរឡើងដល់ធនធាននៅក្នុងតំបន់ និងផ្តល់ផលប្រយោជន៏ដល់សហគមន៏។
ទោះបីជាមានការប្តេជ្ញាធ្វើអោយមានយុត្តិធម៌សំរាប់ប្រជាជននៅតាមជនបទក៏ដោយ ក៏វិធីសាស្ត្រដែលផ្តោតទៅលើការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួពីប្រជាជនមូលដ្ឋាន គឺធ្វើការផ្តោតជាសំខាន់ទៅលើតែការគ្រប់គ្រងនៅថ្នាក់មូលដ្ឋានតែប៉ុណ្ណោះ វាមិនអាចជួយគាំទ្រដល់ការអភិវឌ្ឍន៏ជនបទទៅតាមផ្លូវមួយដោយរលូនគ្រប់ជ្រុងជ្រោយនោះទេ។ សេដ្ឋកិច្ចសង្គមចំរុះទៅតាមយុទ្ធសាស្ត្រនៃការរៀបចំកំលាំងពលកម្មរវាងគ្រួសារ វាមិនបានឆ្លើយតមអោយបានគ្រប់គ្រាន់ទៅនឹងការកំណត់អោយឃើញថាគ្រួសារនៅជនបទអាចដើរតួយ៉ាងសំខាន់ចំពោះការគ្រប់គ្រងធនធានធម្មជាតិទៅតាមបែបផែនផ្សេងៗគ្នានោះទេ (Diepart, 2008a)។ តួនាទីរបស់

គ្រួសារនៅជនបទគឺមិនត្រូវបានបញ្ជាក់ឱ្យបានជាក់លាក់នៅក្នុងគោលនយោបាយអភិវឌ្ឍន៏ជនបទថាពួកគេជាតួអង្គយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនោះទេ ( IFSR, 2004 and Hobley, 2007) ។ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសគមន៏មូលដ្ឋានក៏មានការបរាជ័យផងដែរ ចំពោះការដាក់បញ្ចូលទៅក្នុងបរិបទនៃការអភិវឌ្ឍន៏តំបន់ ដែលនៅក្នុងនោះធនធានធម្មជាតិត្រូវតែមានតុល្យភាពជាមួយការអភិវឌ្ឍន៏កសិកម្ម, ការប្រែប្រួលប្រជាសាស្ត្រ, ឧស្សាហនីយកម្ម, និងការកើនឡើងតួនាទីរបស់ទីផ្សារ (Li, 2002) ។

ប៉ុន្តែវិធីសាស្ត្រផ្សេងៗទៀតមួយចំនួនមិនត្រូវបានយកមកប្រើប្រាស់ច្រើននោះទេ ដោយវិធីសាស្ត្រទាំងនោះមិនបានជួយគាំទ្រដោយផ្ទាល់ទៅដល់សហគមន៏មូលដ្ឋាន ប៉ុន្តែវាអាចចូលរួមចំណែកបំពេញបន្ថែមទៅដល់ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏មូលដ្ឋាន។ តាមរយៈកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការថ្មីដែលបានចេញនូវក្របខ័ណ្ឌមួយដើម្បីជំរុញដល់មុខងារអភិបាលកិច្ចនៅក៏រិតថ្នាក់ស្រុក និងខេត្តបង្កើតបានជាវិធីសាស្ត្រថ្មីមួយបន្ថែមទៀត ដែលអាចយកមកប្រើប្រាស់បានជាពិសេសប្រើប្រាស់សំរាប់ការធ្វើផែនការគ្រប់គ្រងដីធ្លី។ អត្ថបទនេះមានគោលបំណងបង្ហាញអោយឃើញពីចន្លោះប្រហោងនេះដោយប្រើប្រាស់គម្រោងផែនការគ្រប់គ្រងដីធ្លីខេត្តបាត់ដំបងជាមូលដ្ឋាន។

នៅក្នុងអត្ថបទនេះ វានឹងរៀបរាប់ពីវិធីសាស្ត្រសំរាប់ធ្វើគម្រោងផែនការគ្រប់គ្រងដីធ្លីនៅក្នុងខេត្តនិងវិភាគនូវសមិទ្ធផលសំខាន់ៗដែលកើតឡើងពីការងារនេះ។ វាបង្ហាញពីផលប្រយោជន៏ដែលការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏មូលដ្ឋានទទួលបានតាមរយៈការដាក់បញ្ចូលគ្នា នៃការគ្រប់គ្រងធនធានធម្មជាតិថ្នាក់មូលដ្ឋានទៅក្នុងគម្រោងផែនការគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត ដែលការដាក់បញ្ចូលគ្នានេះវានឹងអាចផ្តល់ផលប្រយោជន៏ នឹងអាចជួយដោះស្រាយនូវកង្វះខាតផ្សេងៗដល់វិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៏មូលដ្ឋានដែលអនុវត្តនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។
ទស្សនវិស័យនេះវាដើរស្របទៅតាមសុភាសិតខ្មែរថា : "*ចូលស្ទឹងតាមបត់ ចូលស្រុកតាមប្រទេស*" ដែលបានន័យថាដើម្បីដោះស្រាយបញ្ហាអ្វីមួយត្រូវតែធ្វើការគិតគូរទៅលើ ក្រិត្យក្រមផ្សេងៗដែលទាក់ទងនឹងបញ្ហានេះជាមុនសិន។

## ២. វិធីសាស្ត្រ

### ២.១. ក្របខ័ណ្ឌគោលគំនិត ( Conceptual framework )

ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាពក៏ដូចជាការងារដ៏ទៃទៀតដែរ គឺជាអង្គធាតុយ៉ាងសំខាន់សំរាប់ជំរុញអោយមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព។ ដោយសារតែដីកាន់តែក្សត់ទៅៗ ហើយត្រូវបានយកមកប្រើប្រាស់សំរាប់ការងារជាច្រើននោះ ដូចនេះដីនិងការរប្រើប្រាស់ដីនេះចាំបាច់ត្រូវតែរៀបចំធ្វើផែនការនិងប្រើប្រាស់តាមបែបសមាហរណកម្ម។ នេះវាគួតែធានាដល់ការប្រើប្រាស់ដីធ្លីប្រកបដោយសុទិដ្ឋិនិយម ធានាអោយមានការបែងចែកធនធាននៅលើដីនិងក្រោមដីប្រកបដោយយុត្តិធមិនៅក្នុងសង្គម ដោយមានការប្រុងប្រយ័ត្នដល់ចិរភាពបរិស្ថាន និងធានាអោយមានការគោរពដល់អត្តសញ្ញាណវប្បធម៌។ សរុបមកគោលដៅសំខាន់នោះគឺបង្កើតនូវស្ថានភាពមួយដើម្បីលើកស្ទួយដល់កំរិតជីវភាពរស់នៅរបស់ប្រជាជន ដោយគិតគូទៅដល់ផលប្រយោជន៍និងតំរូវកាផ្សេងៗរបស់ពួកគាត់ (Magel, 2008) ។ នេះរួមមានឱកាសរកការងារធ្វើ ឱកាសក្នុងការប្រើប្រាស់នូវធនធាននៅលើដីនិងក្រោមដីសំរាប់ទ្រទ្រង់ជីវភាពរស់នៅឱកាសទទួលការអប់រំ និងសុខមាលភាព ឱកាសទទួលការកំសាន្តហើយនិងឱកាសទទួលសេវាកម្មដឹកជញ្ជូនដោយងាយស្រួល។ នៅក្នុងសេចក្តីប្រកាសព្រាងស្តីអំពីគោលនយោបាយដីធ្លីរាជរដ្ឋាភិបាលកម្ពុជាបានដាក់នូវទស្សនវិស័យរួមសំរាប់ការគ្រប់គ្រងដីធ្លីនៅក្នុងប្រទេសកម្ពុជា។

ទស្សនវិស័យនេះឈរលើអង្គធាតុបីសំរាប់ធ្វើការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិប្រកបដោយចិរភាព: រដ្ឋបាលដីធ្លី ការបែងចែកដីធ្លី និងការរៀបចំដែនដី (Concil of land policy, 2008)។ គោលគំនិតនៅក្នុងអត្ថបទនេះ គឺវាពឹងផ្អែកយ៉ាងខ្លាំងទៅលើទស្សនវិស័យនៃគោលនយោបាយដីធ្លីនេះ។

រដ្ឋបាលដីធ្លីគឺសំដៅទៅលើការបង្កើតនិងអនុវត្តក្របខ័ណ្ឌច្បាប់ ហើយនិងរចនាសម្ព័ន្ធនៃដំណើរការចុះបញ្ជីដីធ្លីប្រកបដោយចិរភាពទាំងដីរដ្ឋ និងដីឯកជន។ វាក៏មានគោលបំណងបង្កើតនូវប្រព័ន្ធសុរិយោដីរួមមួយដែលអាចប្រើប្រាស់បានច្រើនយ៉ាងសំរាប់ជាមូលដ្ឋានដើម្បីបង្កើតជាប្រព័ន្ធទិន្នន័យភូមិសាស្ត្រថ្នាក់ជាតិ។ ចំណែកការបែងចែកដីធ្លីរួមមានការងារផ្សេងៗដូចជា ការធ្វើបញ្ជីសារពើភ័ណ្ឌដីធ្លី ការបង្កើតយុទ្ធសាស្ត្រ និងផែនការដើម្បីរៀបចំសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ច។ ចំណែកឯសមាសធាតុទី៣នៃគោលនយោបាយដីធ្លីនេះ គឺការរៀបចំដែនដី។ ការរៀបចំដែនដីរួមមានការរៀបចំផែនការគ្រប់គ្រងដីធ្លីនូវកំរិតផ្សេងៗគ្នា ហើយនិងការបង្កើតនូវប្រព័ន្ធរួមមួយសំរាប់ការបែងចែកដីតាមប្រភេទ ព្រមទាំងធ្វើការគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់ដីធ្លី (ក្រាហ្វិច១) ។ ចំពោះគម្រោងផែនការគ្រប់គ្រងដីធ្លីដីធ្លីនៅក្នុងខេត្តបាត់ដំបង គឺផ្តោតទៅលើផ្នែកទីបីនៃគោលនយោបាយដីធ្លីនេះ។ គោលបំណងរួមរបស់ផែនការប្រើប្រាស់ដីធ្លីនេះមានបីផ្នែក(ក្រាហ្វិច១):




*ក្រាហ្វិច១. ក្របខ័ណ្ឌគោលគំនិត (**Conceptual framework**)*

- គម្រោងផែនការនេះ គឺជាឯកសាររៀបចំផែនការគ្រប់គ្រងដីធ្លី សំរាប់ធ្វើការរៀបចំ និងកំណត់នូវបញ្ញត្ត ដើម្បីធ្វើការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។ វាលើកឡើងនូវភាពខុសគ្នាដែលមាននៅក្នុងដែនដីរបស់ខេត្តទៅតាមលក្ខណ:សម្បត្តិរបស់តំបន់ដោយយោងទៅតាមអន្តរអំពើរវាងកត្តាមនុស្ស និងកត្តាធម្មជាតិ។

- គម្រោងផែនការគ្រប់គ្រងដីធ្លីនេះ វាក៏ជាឯកសារសំរាប់គោលនយោបាយដីធ្លី (ដែនដី) របស់ខេត្តផងដែរ។ វាបង្ហាញពីទស្សនវិស័យ និងដំណើរការសកម្មភាពដែលអភិបាលខេត្តបានអនុម័ត និងសំរេច ដើម្បីពង្រឹងដល់ការគ្រប់គ្រងដីធ្លីប្រកបដោយចីរភាព។វាត្រូវបានរៀបចំឡើងទៅតាមដំណើរការមួយដែលមានការពាក់ព័ន្ធទាំងអស់គ្នាជាមួយនិងការធ្វើផែនការជាក់លាក់តាមវិស័យ និងគ្រប់កំរិត ដែលអនុញ្ញាតិដល់ការធ្វើសេចក្តីសំរេចចិត្ត ជាយុទ្ធសាស្ត្រ និងបង្ហាញពីទិដ្ឋភាពរួមនៃធនធាន និងការប្តេជ្ញាអនុវត្ត (CEMAT, 2007)។

-គម្រោងការងារនេះ គឺជាការបង្ហាញអោយឃើញពីការងារអភិបាលកិច្ចនៅក្នុងដែនដីរបស់ខេត្ត បានឆ្លុះបញ្ចាំងនៅក្នុងការកែលំអស្ថាប័ន ដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជាដោយមានកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីបង្កើតនូវរដ្ឋបាលរួមមួយនូវកំរិតថ្នាក់ស្រុកនិងថ្នាក់ខេត្ត។ ក្រុមប្រឹក្សាខេត្តធ្វើការបោះឆ្នោត ជ្រើសរើសដោយក្រុមប្រឹក្សាឃុំហើយនឹងមានការឯកភាពទទួលខុសត្រូវចំពោះការរៀបចំ និងអនុវត្តអោយបានសំរេចនូវផែនការអភិវឌ្ឍន៍ខេត្ត។ គម្រោងផែនការអភិវឌ្ឍន៍រយ:ពេល៥ ឆ្នាំ នឹងមានបញ្ចូលនូវគម្រោងដែលលើកឡើងអំពីគោលការណ៍មូលដ្ឋានសំរាប់ការប្រើប្រាស់និងគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិ។ (មាត្រា ៣៩, ច្បាប់ស្តីអំពីការគ្រប់គ្រង រដ្ឋបាល រាជធានី ខេត្តក្រុង ស្រុក ខណ្ឌ: រាជរដ្ឋាភិបាលកម្ពុជា ២០០៨)

## ២.២. ការធ្វើផែនការ និងការពិភាក្សាជាដំណើរមួយ

ដំណើរការធ្វើផែនការមាន៦ជំហានសំខាន់ៗដែលវាបានធ្វើឡើងក្នុងរយៈពេលជាងមួយឆ្នាំកន្លះ។ ការចូលរួមនិងការពិភាក្សាគឺមានសារសំខាន់ណាស់នៅក្នុងដំណើរការធ្វើផែនការ ដើម្បីធានាឱ្យមានការទទួលស្គាល់បានទូលំទូលាយ។ ការយកចិត្តទុកដាក់ជាសំខាន់នោះ គឺផ្តល់ទៅអោយសំលែងគាំទ្រនៅសហគមន៍ជនបទ។ នៅក្នុងការអង្កេតយ៉ាងស៊ីជំរៅដែលបានធ្វើឡើងនៅក្នុងកំរិតថ្នាក់ភូមិនិងនៅតាមគ្រួសារ ក្នុងគោលបំណងបង្ហាញអោយឃើញពីមុខងារនៅក្នុងសហគមន៍ជនបទទៅតាមបរិបទកេរ្ត៍បរិស្ថានផ្សេងៗគ្នា។

ការចូលរួមចំណែករបស់គ្រួសារនៅក្នុងការគ្រប់គ្រងដីធ្លី គឺបានធ្វើការវាយតំលៃទៅលើចំណេះដឹងរបស់ប្រជាជនមូលដ្ឋាន និងសេដ្ឋកិច្ចសង្គម។ ការសិក្សារទៅតាមប្រភេទនៃប្រព័ន្ធផលិតកម្មនៅជនបទ(នៅកំរិតគ្រួសារ) ត្រូវបានធ្វើឡើងដើម្បីកំណត់អោយឃើញនូវភាពខុសគ្នា នៃយុទ្ធសាស្រ្តក្នុងការបែងចែកកំលាំងពលកម្មនៅតាមគ្រួសារដែលវាតំណាងអោយប្រជាជនទាំងមូលនៅក្នុងខេត្ត។ នេះវាត្រូវបានមើលឃើញថាវាជាល័ក្ខខ័ណ្ឌមុនដំបូងដើម្បីទទួលស្គាល់នូវភាពចំរុះគ្នាដែលមានស្រាប់នៅក្នុងសហគមន៍ជនបទ។

នៅថ្នាក់ស្រុក និងឃុំអាជ្ញាធរមូលដ្ឋានបានរួមចំណែកយ៉ាងខ្លាំងក្នុងការរៀបចំផែនការ ព្រោះពួកគេត្រូវទទួលខុសត្រូវសម្របសម្រួលការងារអភិវឌ្ឍន៏នៅក្នុងដែនដីរបស់គេ នឹងផ្សារភ្ជាប់ទៅនឹងដំណើរការធ្វើផែនការនៅមូលដ្ឋានជាមួយវិស័យឯកជនដែលការចូលរួមរបស់របស់វិស័យឯកជនទាំនោះ គឺតាមធម្មតាវាមានឥទ្ធិពលដល់គ្រួសារនៅជនបទ(Agricultureal product trade, local agri-bussiness )។

មន្ទីរជំនាញក៏ត្រូវបានពិគ្រោះផងដែរនៅក្នុងកំរិតថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ទោះបីជាកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលបំណងបង្កើតនូវរដ្ឋបាលរួមមួយក៏ដោយ ក៏វាមិនបានលុបបំបាត់នូវទំនាក់ទំនងពីលើចុះក្រោមរវាងក្រសួងនីមួយៗ និងភ្នាក់ងារថ្នាក់ជាតិនៅក្រោមឱវាទនោះទេ។ ការជាប់ទាក់ទងគ្នានិងសមាហរណកម្មខ្សែបណ្តោយគឺត្រូវតែមាន ដូចនេះមន្ទីរជំនាញអាចនឹងមានការជាប់ទាក់ទងដោយស្ថាប័ននិងជាថវិកាសំរាប់ការតាមដានផ្តល់អនុសាសន៍ដល់គម្រោងផែនការគ្រប់គ្រងដីធ្លី។

ជាពិសេសនោះដំណើរការធ្វើផែនការ ចាប់ផ្តើមធ្វើឡើងដោយមានអាណត្តិ និងលក្ខ័ន្តិកៈច្បាស់លាស់របស់គណៈកម្មកាប្លង់គោលខេត្តនិងឯកសារបង្គោលរបស់ក្រុមការងារដែលទទួលខុសត្រូវក្នុងការធ្វើផែនការ ។ យុទ្ធសាស្ត្រដោយមានការចូលរួមជាមួយដៃគូធ្វើផែនការ គឺត្រូវមានតាំងពីដំណាក់កាលដំបូងបង្អស់នៃដំណើរការផងដែរ (នៅជំហានទី១) ។

ការសង្ខេបយ៉ាងជាក់លាក់ និងទិន្នន័យដែលទាក់ទងទៅនឹងពតិមានភូមិសាស្ត្រ តួលេខ និងតារាងផ្សេងៗនោះ គឺត្រូវបានប្រមូលផ្តុំ និងវិភាគមុនគេ។ រាល់ទិន្នន័យភូមិសាស្ត្រត្រូវបានដំណើរការ និងប្រមូលផ្តុំតាមផ្នែកសំខាន់ៗ ដូចជា (ផ្នែករដ្ឋបាល ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងហេដ្ឋារចនាសម្ព័ន្ធសង្គម ប្រព័ន្ធកាន់កាប់ដីធ្លី និងប្រពន្ធ័អេក្សូត្របរិស្ថាន) ។ នៅលើមូលដ្ឋាននៃការវិភាគពីបំរែបំរួលនៃការប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់អេក្សូត្របរិស្ថាន គឺត្រូវបានចុះអង្កេតនៅវាលយ៉ាងស៊ីជំរៅដើម្បីធ្វើការស្វែងយល់អោយបានច្បាស់លាស់អំពីបញ្ហានៃការគ្រប់គ្រងដីធ្លីនៅក្នុងកំរិតភូមិ ឃុំ និងនៅតាមគ្រួសារ (តារាង១) (ជំហាន២) ។

*តារាង១: ការរៀបចំចុះអង្កេតនៅវាល*

| *តំបន់អេក្សូត្រ-បរិស្ថាន* | *ឃុំ* | *ចំនួនភូមិដែលធ្វើការវាយតំលៃដោយមានការចូលរួមពីអ្នកភូមិ (PRA)* | *ចំនួនគ្រួសារដែល បានសំភាសន៍* |
|---|---|---|---|
| តំបន់ទំនាបលិចទឹក (ទន្លេសាប) | កំពង់ព្រះ | ៣ | ២០ |
| តំបន់កសិកម្ម(មានសក្តានុពលទាប) | ធិបតី | ៣ | ២៥ |
| តំបន់កសិកម្ម (មានសក្តានុពលខ្ពស់) | តាគ្រាម | ៣ | ២៥ |
| តំបន់កសិ-រុក្ខកម្មចំរុះ | កំពង់ល្ពៅ | ២ | ៣០ |
| តំបន់កសិ-ឧស្សាហកម្ម | តាក្រី | ៣ | ២៤ |

អ្នកពាក់ព័ន្ធទាំងអស់ព្យាយាមបង្កើតនូវទស្សនវិស័យគ្រប់គ្រងដីធ្លីយ៉ាងច្បាស់លាស់ សំរាប់ការអភិវឌ្ឍន៏ខេត្តនាពេលអនាគត។ ទស្សនវិស័យនេះបង្ហាញអំពីការងារដ៏សំខាន់សំរាប់អនាគតដែលនឹងអាចឈានទៅដល់បានក្នុងរយៈពេល២០ឆ្នាំខាងមុខទៀត។ ទស្សនវិស័យជាការកំណត់នូវអ្វីដែលអ្នកពាក់ព័ន្ធទាំងអស់ប្រាថ្នាចង់បាននាពេលអនាគត និងជាការតំណាងអោយនូវអ្វីដែលសហគមន៏ចង់បាន និងខិតខំខិតទៅអោយដល់នាពេលអនាគត (Schalle, 2005) (ជំហានទី៣) ។

ការវិភាគឌីណាមិកត្រូវបានធ្វើឡើងនៅកំរិតថ្នាក់ស្រុកដើម្បីស្វែងយល់នូវលក្ខណៈនៃសណ្ឋានភាពដីបច្ចុប្បន្ន ដែលមានការប្រែប្រួលពីពេលមួយទៅពេលមួយ ហើយនិងនិន្នាការផ្លាស់ប្តូរនាពេលអនាគត (សិក្ខាសាលា ១២ស្រុក ដែលមានអ្នកចូលរួមទាំងអស់ ១៦០ នាក់) ។ ការវិភាគនេះនាំអោយកំណត់បាននូវតំបន់គ្រប់គ្រងដីធ្លីជាក់លាក់ទៅតាមការប្រែប្រួលជាក់លាក់ស្តែង និងបញ្ហាផ្សេងៗដូចជាការការប់ព្រៃឈើ ការអភិវឌ្ឍន៏ទីប្រជុំជនជាដើម។ យោងទៅតាមលក្ខណៈពិសេសនៃតំបន់គ្រប់គ្រងដីធ្លីនីមួយៗតំបន់ទាំងនេះចាត់ទុកជាតំបន់ធ្វើផែនការ(ជំហាន៤) ។

ឈរនៅលើមូលដ្ឋាននេះ យុទ្ធសាស្ត្រនឹងត្រូវបានរៀបចំឡើងសំរាប់តំបន់គ្រប់គ្រងដីធ្លីនីមួយៗ។ វានឹងធ្វើការរៀបចំនូវយុទ្ធសាស្ត្ររួមមួយសំរាប់តំបន់គ្រប់គ្រងដីធ្លី ហើយនិងធ្វើការរៀបចំយុទ្ធសាស្ត្រតាមវិស័យបន្ថែមទៀត ដែលយុទ្ធសាស្ត្រតាមវិស័យនេះ គឺជាការចូលរួមចំណែកពីគ្រប់វិស័យ និងអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការបង្កើតយុទ្ធសាស្ត្រនេះឡើង (ជំហានទី៥)។

ជំហានទី៦ គឺជាការត្រួតពិនិត្យ និងវាយតំលៃ វាជាដំណើរការមួយបន្តទៀតដើម្បីធ្វើការកែលំអរទិន្នន័យ ការធ្វើវិសោធនកម្ម ការដោះស្រាយទំនាស់ដើម្បីគាំទ្រដល់ការអនុវត្តន៍ការងារផ្សេងៗ អោយស្របទៅតាមគោល-នយោបាយរួមដែលបានលើកឡើងនៅក្នុងគម្រោងផែនការគ្រប់គ្រងដីធ្លី(ជំហានទី៦)។

### ២.៣. ដៃគូចូលរួមធ្វើផែនការ

ការរៀបចំធ្វើគម្រោងផែនការនេះ គឺត្រូវបានធ្វើឡើងដោយក្រុមការងារដែលស្ថិតនៅមន្ទីររៀបចំដែនដីនគូបនីយកម្មសំណង់ និងសុរិយោដីខេត្តបាត់ដំបងដោយស្ថិតនៅក្រោមការឧបត្ថម្ភត្រួតពិនិត្យរបស់គណៈកម្មការប្លង់គោលខេត្តដែលមានឯកឧត្តមអភិបាលខេត្តជាប្រធាន។ ហើយវាក៏មានការគាំទ្រពីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់មួយចំនួនផងដែរ ដែលនៅក្នុងនោះរួមមានអង្គការ The Konrad Adenauer Foundation (KAS) ដែលជាដៃគូយ៉ាងសំខាន់របស់រាជរដ្ឋាភិបាលប្រទេសកម្ពុជានៅក្នុងដំណើរការកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈ-ការ ហើយនិងអង្គការសេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់ (DED)។ នៅក្នុងខេត្តបាត់ដំបងតួនាទីសំខាន់របស់អង្គការ (DED) គឺផ្តល់នូវការគាំទ្រដល់ការធ្វើផែនការគ្រប់គ្រងដីធ្លីនូវកំរិតផ្សេងៗគ្នា (ថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ) (Symann, 2008)។ អង្គការ សហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) ក៏មានតួនាទីជួយគាំទ្រផងដែរក្នុងការផ្តល់នូវរូបថតផ្កាយរណប ហើយនិងផ្តល់នូវការគាំទ្រផ្នែកស្ថាប័នយ៉ាងខ្លាំងខ្លានៅថ្នាក់ក្រសួង។

## ៣. លទ្ធផលនៃការការស្រាវជ្រាវ និងលទ្ធផលផែនការ

### ៣.១. ការប្រែប្រួលការប្រើប្រាស់ដីធ្លី ( Land use dynamic )

ការថយចុះគំរបព្រៃឈើយ៉ាងខ្លាំង គឺជាលក្ខណៈដ៏សំខាន់បំផុតនៃការប្រែប្រួលការប្រើប្រាស់ដីធ្លីនាពេលថ្មីៗនេះនៅក្នុងខេត្តបាត់ដំបង(ផែនទី១)។ នៅក្នុងរយៈពេលជាង១៥ឆ្នាំនេះ គំរបព្រៃឈើបានថយចុះពី ៥៦.៨% មកនៅត្រឹមតែ ៤៤.៤% នៃផ្ទៃដីសរុបរបស់ខេត្តបាត់ដំបង។ ការកាប់ព្រៃឈើនេះបានកើតឡើងយ៉ាងខ្លាំងនៅក្នុងតំបន់ខ្ពង់រាបទិសពាយព្យនៃខេត្តបាត់ដំបងដែលនៅទីនោះធនធានព្រៃឈើត្រូវបានបាត់បង់អស់ទាំងស្រុង។




បាតុភាពនៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់នោះកើតឡើងដោយសារតែអន្តរអំពើផ្សេងៗ (ក្រាហ្វិច២) ។ ដោយយោងទៅតាមកិច្ចព្រមព្រៀងសន្តិភាពនៅក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៩០ មជ្ឈមណ្ឌលរដ្ឋបាលស្រុកថ្មីត្រូវបានបង្កើតឡើងនៅភាគពាយព្យនៃខេត្តបាត់ដំបងដែលនៅក្នុងនោះមាន (ស្រុកកំរៀង ស្រុកភ្នំព្រឹក ស្រុកសំ ពៅលូន) ។ ដោយសារតែតំលៃដីនៅតំបន់នេះមានតំលៃថោកប្រសិនបើប្រៀបធៀបទៅនឹងខេត្តផ្សេងៗទៀត បូករួមនឹងលក្ខណៈរបស់ដីល្អនោះ (សណ្ឋានដីល្អ ដីមានជីវជាតិ) បានធ្វើអោយមានការទាក់ទាញគ្រួសារជាច្រើនមករស់នៅក្នុងតំបន់នេះ ហើយគ្រួសារទាំងនោះបានធ្វើចំណាកស្រុកមកពីតំបន់ផ្សេងៗទូទាំងប្រទេសកម្ពុជា ដោយមកតាំងលំនៅដ្ឋានរស់នៅជាអចិន្ត្រៃយ៍ និងប្រកបការងារនៅតំបន់ដីខ្ពង់រាបនេះ (កសិកម្មមិនមែនជាដំណាំស្រូវដូចជា ដំឡូងមី, ពោតក្រហម, សណ្តែកសៀង.......) ។

កំនើនប្រជាជនប្រចាំឆ្នាំជាមធ្យមសំរាប់ខេត្តបាត់ដំបងចន្លោះឆ្នាំ ១៩៩៨ និង ២០០៧ គឺស្មើនឹង ២.៨% ចំណែកស្រុកដែលទើបបង្កើតថ្មីទាំងបីខាងលើនេះមានកំនើនរហូតដល់ ១៩.០១% សំរាប់ស្រុកកំរៀង ១៧.៨៧% សំរាប់ស្រុកភ្នំព្រឹក និង ២.៨៩%សំរាប់ស្រុកសំពៅលូន (ធ្វើការគណនាដោយផ្អែកទៅលើទិន្នន័យឃុំរបស់ក្រសួងផែនការ ២០០៨) ។ កំនើនប្រជជាននៅក្នុងស្រុកនីមួយៗនៃស្រុកទាំងបីនេះអាចបង្ហាញអោយឃើញយ៉ាងច្បាស់ថាកំនើនប្រជាជនទាំងនេះ គឺមករស់នៅអចិន្ត្រៃយ៍នៅក្នុងតំបន់នេះ ។ ដោយកំនើនប្រជាជនយ៉ាងច្រើនបែបនេះហើយ ទើបធ្វើអោយមានតំរូវការដីសំរាប់លំនៅដ្ឋាន និងដីសំរាប់កសិកម្ម ។ ស្របពេលជាមួយគ្នានេះដែររាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ បានចាប់ផ្តើមធ្វើការលើកស្ទួយដល់

ការបង្ករបង្កើនផលនៃដំណាំយុទ្ធសាស្ត្រ និងដំណាំឆ្លងកាត់ (ដូចជាពោតក្រហម ដំឡូងមី សណ្តែកសៀង អំពៅ និងកៅស៊ូ) សំរាប់ការកែឆ្នៃក្នុងស្រុកនិងនាំចេញ។ គោលនយោបាយនេះបានធ្វើអោយអ្នកវិនិយោគនៅក្នុងប្រទេសនិងក្រៅប្រទេសមកធ្វើការវិនិយោគលើវិស័យកសិឧស្សាហកម្មដោយប្រមូលទិញ ស្តុកទុក និងកែឆ្នៃផលិតផលដំណាំកសិកម្មទាំងនេះ។ ដោយការអភិវឌ្ឍន៍នៃប្រពលវប្បកម្មកសិកម្មនៅក្នុងតំបន់ខ្ពង់រាបនៅតែពឹងផ្អែកទៅលើកំលាំងពលកម្មរបស់មនុស្សនោះ ការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យកសិកម្មនៅក្នុងតំបន់នេះបានជំរុញអោយមានចំនួលស្រុកមកកាន់តំបន់ទាំងនេះ(ក្រាហ្វិច២)។ ការប្រែប្រួលទាំងមូល នៃការពង្រីកលំនៅដ្ឋាន និងការអភិវឌ្ឍន៍កសិម្ម (ចំការ) បានធ្វើអោយមានភាពអន្តរាយដល់គំរបព្រៃឈើ។




*ក្រាហ្វិច២: ទំរង់នៃការវិវត្តន៏ការប្រែប្រួលការប្រើប្រាស់ដីធ្លីនៅក្នុងខេត្តបាត់ដំបង (១៩៩៣-២០០៨)*

រូបភាពនេះពន្យល់ពីការកាប់ព្រៃឈើដែលត្រូវបានកំណត់នូវចំណុចកណ្តាលនៃរូបភាពនេះ (↓ គំរបព្រៃ) ។ វាមានភាពផ្សេងៗគ្នារវាងមូលហេតុ និងផលវិបាកនៃការកាប់ព្រៃឈើ ដែលមានបង្ហាញនូវផ្នែកខាងឆ្វេង និងខាងស្តាំនៃប្រអប់ដែលនៅចំកណ្តាលរូបភាពនេះ ។

បើនិយាយពីទំនាក់ទំនងគ្នានៃការកាន់កាប់ដីធ្លី គំរបព្រៃឈើមានការថយចុះដោយសារការអភិវឌ្ឍន៏កសិកម្មដំណាំឆ្លងកាត់នៅក្នុងតំបន់ខ្ពង់រាបដែលជាការបង្ហាញនូវការធ្វើឯកជនកម្មក្រៅផ្លូវការនៃដីសារធារណៈរបស់រដ្ឋ និងការធ្លាក់ចុះនៃការគ្រប់គ្រងធនធានធម្មជាតិរួម ។

នៅក្នុងប្រទេសកម្ពុជា បញ្ហានៃការបង្កើនផលិតកម្មស្រូវអោយស្របតាមអត្រាកំនើនប្រជាជននោះ តែងតែធ្វើការដោះស្រាយដោយពង្រីកផ្ទៃដីដាំដុះបន្ថែម ។ ប៉ុន្តែដោយសព្វថ្ងៃនេះមិនអាចរកនូវផ្ទៃដីពង្រីកបន្ថែមសំរាប់កសិកម្មបាននោះទេ ដូចនេះប្រព័ន្ធកសិកម្មគឺវាស្ថិតនៅក្នុងផ្លូវបត់មួយ (Dupuis, 2008)។ ដូចនេះបញ្ហាចំពោះប្រជាជននៅតាមជនបទធ្វើការបង្កើនផលិតកម្មស្រូវនោះ តម្រូវឱ្យធ្វើទៅតាមបែបប្រពលវប្បកម្មកសិកម្ម ដោយធ្វើការដាំដុះពីរដងក្នុងមួយឆ្នាំនៅលើផ្ទៃដីដដែល ។ ការធ្វើប្រពលវប្បកម្មកសិកម្មនេះបានធ្វើអោយប្រសើរដល់បច្ចេកទេសគ្រប់គ្រងទឹក ( ឧទាហរណ៏ៈប្រឡាយបង្ហូរទឹក និងប្រព័ន្ធធារាសាស្ត្រ )។ ការគ្រប់គ្រងដោយសហគមន៏មានតួនាទីយ៉ាងសំខាន់ចំពោះការអនុវត្តន៏នូវបច្ចេកទេសនេះ ។

ទោះបីជាការអភិវឌ្ឍន៏កសិកម្មអាចធ្វើអោយចំណូលរបស់គ្រួសារកសិករមានការកើនឡើងក៏ដោយ (ចំណូលដែលបានមកពីកសិកម្មមានចំណូលច្រើនបំផុតគឺនៅតំបន់ខ្ពង់រាបទាំងនេះ) តែការបាត់បង់នូវគំរបព្រៃឈើបានផ្តល់នូវផលវិបាកបាត់បង់ផលប្រយោជន៏ដល់សហគមន៏មូលដ្ឋាន ។ ការកាប់បំផ្លាញព្រៃឈើធ្វើអោយមានការគំរាមកំហែង

ដល់ជីវៈចំរុះ (សត្វ និងរុក្ខជាតិ) ដែលមានឥទ្ធិពលដល់ផលិតផលព្រៃឈើចំរុះដែលគ្រួសារនៅជនបទអាចទាញយកផលប្រយោជន៍ពីផលិតផលព្រៃឈើទាំងនោះបាន។ ហើយមានផលប៉ះពាល់ដោយផ្ទាល់ទៅដល់សេដ្ឋកិច្ចរបស់គ្រួសារដែលរស់នៅពឹងផ្អែកទៅលើធនធានព្រៃឈើដែលជាធនធានដ៏ចាំបាច់ និងមានសុវត្ថិភាពសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។




*ក្រាហ្វិច៣: របាយចំណូលទៅតាមចំណាត់ថ្នាក់ទ្រព្យ និងពីប្រភពផ្សេងៗ ( គ្រួសារនៅជនបទ )*

ដោយផ្អែកទៅលើទិន្នន័យដែលបានមកពីការអង្កេតសេដ្ឋកិច្ចសង្គមប្រទេសកម្ពុជា២០០៤ បានធ្វើការវិភាគសំរាប់ខេត្តបាត់ដំបងទាំងមូលនោះបានបង្ហាញអោយឃើញថា គ្រួសារក្រីក្របំផុតនៅក្នុងខេត្តបាត់ដំបង គឺរស់នៅពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានសាធារណៈ (ជាពិសេសធនធានព្រៃឈើ)ជាងធនធានណាៗទាំងអស់ (ក្រាហ្វិច៣)។ ម្យ៉ាងវិញទៀតការកាប់បំផ្លាញព្រៃឈើបានធ្វើអោយមានភាពប្រថុយប្រថានចំពោះការអភិវឌ្ឍន៏កសិកម្មប្រកបដោយចីរភាពដោយសារតែការបាត់បង់ព្រៃឈើ វាធ្វើអោយមានផលប៉ះពាល់ដល់ទីជំរាលទាំងមូល។ ការកាប់បំផ្លាញព្រៃឈើធ្វើអោយមានការថយចុះនូវក៏រិតទឹកក្រោមដី ដោយមិនអាចជៀសផុតដល់ការបាត់បង់ជីវជាតិដី និងទឹកសំរាប់ការទ្រទ្រង់ដល់រុក្ខជាតិ។ ហើយវាក៏មានគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ព្រមទាំងការហូរច្រោះមានការកើនឡើងផងដែរ។ លើសពីនេះទៅទៀតការបាត់បង់ព្រៃឈើបានធ្វើអោយមានការថយចុះនូវឱកាសសំរាប់ការអភិវឌ្ឍន៏សេដ្ឋកិច្ចតាមរយៈអេកូទេសចរណ៏ (ជាពិសេសនៅតាមដងស្ទឹង) ដែលជាធនធានមួយយ៉ាងសំខាន់សំរាប់ការអភិវឌ្ឍន៏សេដ្ឋកច្ចិសង្គមនៅក្នុងខេត្តបាត់ដំបង។

## ៣.២. ការកំណត់តំបន់គ្រប់គ្រងដីធ្លី

ការបែងចែកតំបន់គ្រប់គ្រងដីធ្លី (ផែនទី២) គឺមានការបែងចែកដែនដីរបស់ខេត្តទៅជាតំបន់នីមួយៗដែលមានលក្ខណៈប្រើប្រាស់ដីធ្លីដូចៗគ្នា (Homogeneous Land Unit)។ វាមានគោលបំណងកំណត់នូវតំបន់ជាក់លាក់ដែលមានភាពខុសគ្នាដាច់ដោយឡែកនៅក្នុងដែនដីខេត្តបាត់ដំបងដោយយោងទៅតាមៈ ១.ល័ក្ខខ័ណ្ឌភ្សេត្របរិស្ថាន ២.ការប្រែប្រួលការគ្រប់គ្រងដីធ្លីនាពេលបច្ចុប្បន្ន ដែលវាមានឥទ្ធិពលដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីធ្លីនាពេលថ្មីៗនេះ។

ការពិភាក្សាគ្នាជាមួយអ្នកពាក់ព័ន្ធជាច្រើននៅតាមស្រុកនីមួយៗ បានឈានទៅដល់ការកំណត់នូវលក្ខណៈវិនិច្ឆ័យដើម្បីកំណត់បាននូវតំបន់នីមួយៗដោយមានការឯកភាពទៅលើព្រំប្រទល់របស់តំបន់ទាំងនេះ និងធ្វើការវិភាគពីបញ្ហាគន្លឹះនៃការគ្រប់គ្រងដីធ្លីសំរាប់តំបន់ទាំងនេះដោយស្វែងរកនូវឫសគល់នៃមូលហេតុ និងផលវិបាករបស់បញ្ហានីមួយៗ។ និយាយសរុបមកការបែងចែកតំបន់ដីធ្លីដែលបានធ្វើឡើងនៅក្នុងស្រុកនីមួយៗ ត្រូវបានដាក់បញ្ចូលគ្នាបង្កើតបានជាការបែងចែកតំបន់នៅក្នុងថ្នាក់ខេត្តទាំងមូល។ តំបន់នីមួយៗគឺវាមានលក្ខណៈពិសេសរៀងៗខ្លួនដូចនេះវាដើរតួជាតំបន់សំរាប់ធ្វើផែនការ។ ដំណាក់កាលដំបូងគឺត្រូវធ្វើការវិភាគទៅលើបញ្ហាស្នូលនៃការគ្រប់គ្រងដីធ្លី ពីឫសគល់នៃបញ្ហានិងផលវិបាកសំរាប់តំបន់នីមួយៗ។ បន្ទាប់មកយុទ្ធសាស្ត្រអភិវឌ្ឍន៍អន្តរវិស័យត្រូវបានរៀបចំឡើងទៅតាមនោះដែរ ដោយមានការចូលរួមចំណែកពីស្ថាប័នពាក់ព័ន្ធនីមួយៗនៅក្នុងដំណើរការធ្វើផែនការ។ ការងារ អាទិភាពមួយចំនួនត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាទាំងនេះក្នុងលក្ខណៈស៊ីចង្វាក់គ្នា។




នៅក្នុងអត្ថបទនេះវាមិនបានធ្វើការរៀបរាប់អោយលំអិតអពីតំបន់គ្រប់គ្រងដីធ្លីនីមួយៗ និងការកំណត់នូវវិធីសាស្ត្រធ្វើផែនការនោះទេ។ វាធ្វើការផ្តោតជាសំខាន់ទៅលើផលប្រយោជន៍នៃការបែងចែកតំបន់គ្រប់គ្រងដីធ្លីរួមដែលវាពង្រឹងទៅដល់វិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន ហើយនិងជួយពង្រឹងដល់ការទប់ស្កាត់នៃការថយចុះធនធានព្រៃឈើ។

- នៅក្នុងតំបន់ចំរុះកសិ-ឧស្សាហកម្ម និងព្រៃឈើ ការការពារព្រៃឈើជាតំរូវការដ៏សំខាន់ ពីព្រោះវាជាប្រភពដ៏សំខាន់នៃផលនិងអនុផលព្រៃឈើសំរាប់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ប៉ុន្តែក៏ព្រោះតែវាជួយដល់ការការគ្រប់គ្រងទីជំរាល ហើយជាអ្នកធានាដល់ការអភិវឌ្ឍន៏វិស័យកសិកម្មប្រកបដោយចិរភាពផងដែរ។ ការរៀបចំធ្វើការគ្រប់គ្រងតំបន់នេះនាពេលអនាគតគឺបានផ្តល់មូលដ្ឋានគ្រឹះសំរាប់កំណត់នូវតំបន់ជាច្រើនដែលមានសក្តានុពលសំរាប់បង្កើតជាសហគមន៍ព្រៃឈើ។ តំបន់សក្តានុពលសំរាប់សហគមន៍ព្រៃឈើត្រូវបានកំណត់ ហើយនឹងបញ្ចូលទៅក្នុងសំណើស្នើទៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ។ គោលបំណងនៃដំណើរការនេះគឺមានពីរ វាមានគោលបំណងផ្តល់នូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដល់សហគមន៍ជនបទ ដើម្បីធ្វើការគ្រប់គ្រងផ្នែកដែលនៅសល់ព្រៃឈើ ប៉ុន្តែវាក៏ត្រូវតែធ្វើការពិចារណាអំពីការការពារព្រៃឈើ ទៅតាមទំហំមួយដែលវាអាចផ្តល់នូវផលប្រយោជន៍សំរាប់ការអភិវឌ្ឍន៏កសិកម្មហើយនិងសំរាប់ការគ្រប់គ្រងទឹកនៅទីជំរាលផ្នែកខាងក្រោមផងដែរ។

- តំបន់ការពារទេសភាពតាមានគោលបំណងធ្វើការពង្រឹងដល់ការគ្រប់គ្រងធនធានទឹក និងតាមដងស្ទឹងដែលជាតំបន់ដែលផ្តល់នូវឱកាសយ៉ាងសំខាន់សំរាប់អេកូទេសចរណ៏នៅសហគមន៍មូលដ្ឋាន។ ដំណើការរៀបចំសំរាប់ធ្វើការគ្រប់គ្រងនាពេលអនាគតនៅក្នុងតំបន់នេះ គឺបានផ្តល់នូវមូលដ្ឋានគ្រឹះសំរាប់តំបន់អេកូទេសចរណ៏យ៉ាងសំខាន់ (តំបន់កំសាន្តបែបបរិស្ថានដែលមានទ្រង់ទ្រាយតូច) ដែលត្រូវបានចាត់ទុកថាជាសសរស្តម្ភមួយ នៃយុទ្ធសាស្រ្តអភិវឌ្ឍន៏វិស័យទេសចរណ៏នៅខេត្តបាត់ដំបង។ ផែនការដែលបានអនុម័តដោយអភិបាលខេត្តនៅក្នុងនោះមានតំបន់អេកូទេសចរណ៏ចំនួន១៦កន្លែង ដែលជាការចូលរួមចំណែករបស់សហគមន៍ ហើយតំបន់ទាំងនោះត្រូវបានធ្វើការកំណត់យ៉ាងច្បាស់លាស់(គណៈកម្មការប្លង់គោលខេត្ត, ២០០៨)។

- គម្រោងផែនការគ្រប់គ្រងដីធ្លី ក៏បានលើកឡើងនូវការកំណត់ឡើងវិញនៃតំបន់ការពារនាមដូនសំ អោយស្របទៅតាមបំលាស់ទីរបស់ប្រជាជនដែលមករស់នៅថ្មីនៅក្នុងតំបន់នេះ។ ដាយសារតែវាមានផលប៉ះពាល់ជាអវិជ្ជមានតាមរយៈការរំលោភបំពានកាប់បំផ្លាញព្រៃឈើដើម្បីធ្វើការអភិវឌ្ឍន៏កសិកម្មដំណាំឆ្លងកាត់ និងសេដ្ឋកិច្ចគ្រួសារនោះការការពារព្រៃឈើ និងការគ្រប់គ្រងទីជំរាលពិតជាមានអត្ថន័យខ្លាំងណាស់ដល់ផ្នែកសេដ្ឋកិច្ច ពីព្រោះវាមាននិន្នាការថែរក្សារដល់សក្តានុពលសំរាប់ការអភិវឌ្ឍន៏កសិកម្មរយៈពេលយូរអង្វែងនៅក្នុងតំបន់។ ដើម្បីស្វែងរកនូវតុល្យភាពរវាងតំរូវការដីសំរាប់លំនៅដ្ឋាននិងតំរូវការដីសំរាប់កសិកម្ម និងការការពារព្រៃឈើគឺការធ្វើផែនការកំណត់ឡើងវិញនូវតំបន់ដាក់លាក់ដែលមានស្រាប់នៅក្នុងតំបន់ការពារ ដើម្បីធ្វើការការពារព្រៃឈើដែលនៅសល់និងរៀបចំបង្កើតដីសម្បទានសង្គមកិច្ចនៅក្នុងតំបន់ដទៃទៀត។

## ៤. ការពិភាក្សា

បញ្ហាដែលលើកឡើងនៅក្នុងអត្ថបទនេះ គឺការដាក់បញ្ចូលគ្នានូវគំនិតនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ទៅក្នុងគម្រោងផែនការគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត គឺអាចពង្រឹងដល់ការងារមូលដ្ឋាន ហើយនិងផ្តល់ការ

ទទួលស្គាល់យ៉ាងខ្លាំងដល់សហគមន៍ ។ យើងលើកឡើងការពិភាក្សាពីគំនិតស្នូលនេះស្របទៅតាមទិសដៅបីសំខាន់ៗនៃគម្រោងផែនការគ្រប់គ្រងដីធ្លី។

## ៤.១. ផែនការប្រើប្រាស់ដីធ្លី

អន្តរអំពើរវាងសមាសភាពធម្មជាតិផ្សេងៗគ្នា នៃប្រព័ន្ធកសិបរិស្ថានបានកំណត់នូវមុខងារ និងការផលិតឡើងវិញរបស់វា។ ដូចនេះការវាយតំលៃទៅលើកត្តាខាងក្រៅដែលធ្វើការគ្រប់គ្រងមិនបានល្អនៅក្នុងសមាសភាពណាមួយនោះវាអាចមានឥទ្ធិពលទៅលើសមាសភាពផ្សេងៗទៀត ដែលវាជាកត្តាដ៏សំខាន់ ដែលធ្វើអោយមានមានការប្រែប្រួលទៅដល់ប្រព័ន្ធកសិ-បរិស្ថាន។ ទំហំនៃការវាយតំលៃនេះគឺបង្កើតជាបញ្ហាយ៉ាងធំ ។ អន្តរអំពើទាំងនេះអាចរកឃើញហើយដោះស្រាយបានដោយធ្វើការសិក្សាក្នុងកំរិតតំបន់មួយធំ ដើម្បីធ្វើការថ្លឹងថ្លែងអំពីឥទ្ធិពលនៃសមាសភាពធនធានទាំងនេះដែលវាមានទៅលើគ្នាទៅវិញទៅមក។ ឧទាហរណ៍ការរំលោភបំពានកាប់បំផ្លាញព្រៃឈើជះឥទ្ធិពលទៅដល់សក្តានុពលកសិកម្ម មានឥទ្ធិពលលើកំរិតទឹកក្រោមដី និងលំហូទឹកនៅផ្នែកខាងក្រោមៗនៃតំបន់ទីជំរាល ឬមានឥទ្ធិពលទៅដល់អាកាសធាតុនៅក្នុងតំបន់ គឺអាចធ្វើការវាយតំលៃបានល្អដ៏រាបណាធ្វើការសិក្សាក្នុងកំរិតមួយធំលើសពីកំរិតថ្នាក់ឃុំ និងថ្នាក់ស្រុក (ឧទាហរណ៍: ការធ្វើផែនការសំរាប់ខេត្តមួយ)។

លើសពីនេះទៅទៀត ការលើកឡើងពីការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងក្របខ័ណ្ឌខេត្តយ៉ាងទូលំទូលាយទាក់ទងទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាននោះ វាបានបង្ហាញឱ្យឃើញពីតុល្យភាពគ្នាររវាងតម្រូវការរយៈពេលខ្លីរបស់សហគមន៍ដែលទាញយកពីធនធានធម្មជាតិជាមួយនិងសេវាកម្ម និងផលប្រយោជន៍យូរអង្វែដែលប្រព័ន្ធបរិស្ថានផ្តល់អោយ។ ផែនការគ្រប់គ្រងដីធ្លីថ្នាក់ខេត្តវាអាចបង្ហាញនូវទិដ្ឋភាពទូលំទូលាយជាងផែនការប្រើប្រាស់ដីធ្លីថ្នាក់ឃុំ។ អត្ថបទបានបង្ហាញជាឧទាហរណ៍ថាការអភិវឌ្ឍន៍វិស័យកសិកម្មដោយផ្សារភ្ជាប់ជាមួយនឹងការវិនិយោគកសិឧស្សាហកម្មយ៉ាងខ្លាំ ហើយនិងចំណូលស្រុក អាចយល់បានល្អប្រសើរ និងអាចវិភាគទៅបានគឺត្រូវធ្វើការសិក្សានៅក្នុងកំរិតថ្នាក់ខេត្ត។ នៅក្នុងទំហំនេះ(កំរិតថ្នាក់ខេត្ត)គឺវាសមហេតុផលមែនទែន ដោយវាអាចធ្វើការដោះស្រាយនូវបញ្ហានានាដែលនៅកំរិតថ្នាក់ក្រោមមិនអាចធ្វើការដោះស្រាយបាន(ឧទាហរណ៍ដូចជា: នៅកំរិតថ្នាក់ស្រុក ថ្នាក់ឃុំ)។

លទ្ធផលសរុបរវាងអំពើរបស់គ្រួសារនីមួយៗ (ឧទាហរណ៍ កាប់ដីឆ្ការដីព្រៃដើម្បីដោះស្រាយជីវភាព) វាកត្តាដែលធ្វើអោយប៉ះពាល់ទៅដល់ប្រព័ន្ធកសិបរិស្ថានដោយទទួលនូវផលជាអវិជ្ជមាន មិនអាចស្តារអោយបានដូចដើមបានឡើយទៅលើប្រព័ន្ធផលិតកម្មរបស់គ្រួសារទាំងនោះ។ តួនាទីផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្តគឺដើម្បីកំណត់នូវក្របខ័ណ្ឌអោយបានសមស្រប ថាតើនៅកំរិតណាដែលគួរបណ្តោយអោយថ្នាក់មូលដ្ឋានធ្វើការសំរេចចិត្តបាន ហើយនៅកំរិតណាដែលគួរតែធ្វើការហាមឃាត់ ដើម្បីធានានូវការបង្កបង្កើនផលរយៈពេលយូរអង្វែងរបស់សហគមន៍

ជនបទ។ ជាឧទាហរណ៍ៈ ដំណើរការធ្វើផែនការគ្រប់គ្រងដីធ្លីថ្នាក់ខេត្តត្រូវបានប្រើជាឧបករណ៍ដើម្បីកំណត់នូវការផ្តល់សិទ្ធដល់សហគមន៍ជា សហគមន៍ព្រៃឈើ ឬក៏ដីតំបន់អេកូទេសចរណ៍នៅក្នុងមូលដ្ឋាន។

ទោះបីជាយ៉ាងណាក៏ដោយ វាគួតែបញ្ជាក់ផងដែរថាគម្រោងផែនការគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត គឺជាសមាសធាតុមួយដែលមានសារៈសំខាន់ ប៉ុន្តែវាម្នាក់ឯងគឺមិនគ្រប់គ្រាន់សំរាប់ផ្តល់នូវប្រសិទ្ធភាពគ្រប់គ្រងដីធ្លីប្រកបដោយចីរភាពនោះទេ។ ដូចនេះវាគួរតែស្ថិតក្នុងគម្រោងផែនការមួយធំទូលាយជាងនេះទៀត ឧទាហរណ៍ៈ គម្រោងផែនការគ្រប់គ្រងដីធ្លីថ្នាក់ជាតិ។ គម្រោងផែនការគ្រប់គ្រងដីធ្លីថ្នាក់ជាតិនេះគឺនៅតែមិនទាន់មាននៅឡើយនោះទេ។ ម្យ៉ាងវិញទៀតគម្រោងផែនការគ្រប់គ្រងដីធ្លីខេត្ត គួរតែកំណត់និងធ្វើផែនការលំអិតបន្ថែមទៀតទៅជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ស្រុក ឬក៏កាន់តែលំអិតថែមទៀតជាផែនការប្រើប្រើប្រាស់ដីធ្លីលំអិតថ្នាក់ឃុំដែលមានរួមបញ្ចូលផ្នែកច្បាប់ (ស្ថិតនៅក្នុងការរងចាំការអនុម័តអនុក្រិត្យស្តីអំពីផែនការប្រើប្រាស់ដីធ្លីថ្នាក់ឃុំដែលវានឹងផ្តល់នូវមូលដ្ឋានគ្រឹះផ្នែកច្បាប់)។

## ៤.២. គោលនយោបាយដែនដី

ការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា គឺវានៅមានភាពចន្លោះប្រហោងរវាងក្របខ័ណ្ឌច្បាប់ (តួនាទីរបស់ស្ថាប័ន) និងការអនុវត្តច្បាប់ (តួនាទីប្រតិបត្តិ) ដែលកំណត់នូវយន្តការសំរាប់ការបែងចែកធនធានដែលមាននៅលើដី។ ឧទាហរណ៍ៈ តើធនធានទាំងនោះគួរយកមកប្រើប្រាស់នៅពេលណា នៅកន្លែងណា និងដោយរបៀបណា នរណាគួរតែធ្វើការត្រួតពិនិត្យទៅលើសកម្មភាពបែងចែកធនធានទាំងនោះ ពតិមានអ្វីខ្លះគួរធ្វើការផ្លាស់ប្តូរ ហើយគួរទទួលរង្វាន់ឬគួរដាក់ទណ្ឌកម្មបែបណាចំពោះការប្រព្រឹត្ត និងលទ្ធផលដែលកើតមានឡើង (Ostrom, 2002)។ ចន្លោះប្រហោងនេះគួតែធ្វើការបំពេញបន្ថែមជាមួយការគាំទ្រគោលនយោបាយដែលកំណត់នូវជំរើសសំខាន់ដើម្បីបង្ហាញអំពីទំនាក់ទំនងទៅវិញទៅមករវាងសមាសភាពនៃធនធានទាំងនោះ ហើយនិងការលើកស្ទួយដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពអោយដើរទន្ទឹមជាមួយលក្ខណៈពិសេសដាច់ដោយឡែក ដែលមាននៅក្នុងតំបន់នីមួយៗក្នុងដែនដីរបស់ខេត្ត។ ដោយសារតែមានច្បាប់តាមវិស័យនីមួយៗ យុទ្ធសាស្រ្ត ការសំរេចចិត្ត និងផែនការជាច្រើនស្ថិតនូវកំរិតខុសៗគ្នាវាបានធ្វើអោយការងារនេះមានដំណើរការអោយចេញផុតពីវិស័យនីមួយៗនោះ មានការលំបាកមែនទែន។

វាចាំបាច់ត្រូវចែករំលែកនៃការយល់ដឹងអោយបានស៊ីជំរៅរវាងអ្នកពាក់ព័ន្ធទាំងអស់ អំពីបញ្ហានៃការគ្រប់គ្រងដីធ្លីផ្សេងៗគ្នាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍន៍នៅក្នុងដែនដីរបស់ខ្លួន។ ហើយវាក៏ត្រូវតែធ្វើការកំណត់នូវទស្សនវិស័យអោយបានច្បាស់លាស់ដើម្បីធ្វើការសំរេចចិត្តប្រកបដោយប្រសិទ្ធិភាព។ ការកែលំអស្ថាប័នដែលលើកឡើង

នៅក្នុងអត្ថបទនេះបានបង្ហាញថាខេត្ត គឺជាកំរិតដំបូងសំរាប់បំពេញតួនាទីរ នៃការរៀបចំគោលនយោបាយដែនដីនេះ។ ខេត្តគឺបានធ្វើនូវវិមជ្ឈការគ្រប់គ្រាន់ ធ្វើអោយបានល្អដល់ល័ក្ខខ័ណ្ឌមូលដ្ឋានហើយនិងបង្ហាញពីទំនាក់ទំនងទៅវិញទៅមករវាងសមាសភាពប្រព័ន្ធកសិបរិស្ថានផ្សេងៗ ហើយនៅក្នុងពេលស្របជាមួយគ្នានេះដែរ គឺវាមានលក្ខណៈគ្រប់គ្រាន់សំរាប់ជាចំនុចចាប់ផ្តើមធ្វើការងារដោយផ្តល់នូវអំនាចថ្មី ដែលផ្ទេរមកអោយភ្នាក់ងារនៅថ្នាក់ខេត្តដែលជាផ្នែកមួយ នៃកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ។

នៅពេលធ្វើការកំណត់នូវទស្សនវិស័យអ្នកពាក់ព័ន្ធទាំងអស់បានយល់ព្រមថា ការលើកស្ទួយដល់ការអភិវឌ្ឍន៍នៅជនបទដោយសហគមន៍មូលដ្ឋានគឺជាសសរស្តម្ភមួយ នៃគោលនយោបាយដែនដី។ វាបានន័យថាការចូលរួមពីអ្នកមូលដ្ឋាននៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ មិនត្រឹមតែជាឱកាសដែលសហគមន៍មួយចំនួនអាចទទួលការគាំទ្រពី NGOs ប៉ុន្តែវាក្លាយទៅជាសិទ្ធមួយដែលត្រូវតែគោរព។ ជាចំណុចចាប់ផ្តើម វាមានគោលបំណងទទួលស្គាល់ថាសហគមន៍ជនបទមិនត្រឹមតែជាគោលដៅ នៃការអភិវឌ្ឍន៍នោះទេ ប៉ុន្តែវាជាអ្នកដើរតួយ៉ាងពិតប្រាកដនៅក្នុងការអភិវឌ្ឍន៍ជនបទ។ លើសពីនេះទៅទៀត វាក៏ផ្តល់នូវការទទួលស្គាល់បន្ថែមទៀត សំរាប់ការផ្តួចផ្តើម នៃសហគមន៍ដែលអាចនឹងបង្កើនដល់សុវត្ថិភាព នៃការកាន់កាប់ដីធ្លីរបស់សហគមន៍។

## ៤.៣. អភិបាលកិច្ចដែនដី

អភិបាលកិច្ចដែនដីកំណត់នូវមធ្យោបាយថាតើគោលនយោបាយដែនដីត្រូវអនុវត្តទៅដោយរបៀបណា។ បញ្ហានោះគឺវាមានពីរ ហើយវាទាក់ទងជាមួយនឹងកំណែទំរង់ស្ថាប័នទាំងស្រុង ដែលកំពុងតែអនុវត្តនៅក្នុងប្រទេសកម្ពុជានៅក្នុងក្របខ័ណ្ឌកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ។ វគឺស្ថិតនៅក្នុងការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនូវកំរិតណាមួយ (សមាហរណកម្មខ្សែទទឹង) ហើយនិងការបែងចែកតួនាទីនិងអំនាចគ្រប់កំរិត (សមាហរណកម្មខ្សែបណ្តោយ)។

សមាសភាពនីមួយៗ នៃប្រព័ន្ធកសិ-បរិស្ថាន គឺប្រមូលផ្តុំគ្នាទៅជាវិស័យមួយ នៃរដ្ឋបាលសាធារណៈសំរាប់ការគ្រប់គ្រង ប៉ុន្តែជាក់ស្តែងដំណើការនិងអន្តរអំពើរវាងសមាសភាពទាំងនោះ គឺមានភាពទន់ខ្សោយដោយវាបង្ហាញអោយឃើញតាមរយៈការជជែកគ្នារវាងរដ្ឋបាលទាំងនោះ។ លើសពីនេះទៅទៀតវាត្រូវបានទទួលស្គាល់យ៉ាងទូលាយថា ការកើនឡើង នៃគំរោងតាមរយៈជំនួយធ្វើការបង្កើតនិងអនុវត្តដោយគ្មានការសម្របសម្រួលជាមួយផែនការរបស់មន្ទីរខេត្តធ្វើអោយមានការប៉ះពាល់ដល់ការទទួលខុសត្រូវរបស់មន្ទីរ ដោយវាមានទិសដៅផ្ទុយពីមុខងារស្នូលរបស់មន្ទីរទាំងនោះ (Horng and Craig, 2008) គម្រោងផែនការគ្រប់គ្រងដីធ្លីផ្តល់នូវគំនិតគោលថ្មីសំរាប់សម្របសម្រួលអភិបាលកិច្ចដែនដី។ គំនិតថ្មីនេះបានបើកទូលាយដល់អ្នកពាក់ព័ន្ធទាំងអស់អាចបញ្ចេញមតិ ហើយបញ្ចូលការពិភាក្សានេះអោយទៅក្នុងដំណើរការធ្វើផែនការពិតប្រាកដ។ វាប្រមើលមើលនូវការងារមួយ

ដែលក្រុមប្រឹក្សាខេត្តនឹងធ្វើការគាំទ្រដែលជាការរៀបចំគោលការណ៍មូលដ្ឋាន សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ និងដីធ្លីប្រកបដោយចីរភាព។អ្វីដែលមិនទាន់ច្បាស់នោះគឺថាតើកម្មវិធីវិនិយោគសាធារណៈ(PIP)និងត្រូវធ្វើអោយមានភាពផ្សារភ្ជាប់យ៉ាងមាំទៅនឹងគម្រោងផែនការប្រើប្រាស់ដីធ្លីនាពេលអនាគតដោយរបៀបណា។

ផលប្រយោជន៍នៃការសម្របសម្រួលនេះពិតជាមានជាក់ស្តែងមែន។ ដំណើរការចង្អុលបង្ហាញពីការសម្របសម្រួលនៃការប្រើប្រាស់ និងការបែងចែកទិន្នន័យភូមិសាស្រ្តរវាងអ្នកពាក់ព័ន្ធ (វិស័យសាធារណៈ វិស័យឯកជន និងផ្នែកបញ្ញាជន)។ បណ្តុំទិន្នន័យភូមិសាស្រ្តអន្តរវិស័យបានធ្វើការប្រមូលផ្តុំឡើងក្នុងកំឡុងពេលដំណើរការធ្វើផែនការវាបង្កើតជាប្រព័ន្ធទិន្នន័យមូលដ្ឋានភូមិសាស្រ្តសំរាប់ថ្នាក់ខេត្ត ហើយវាតំណាងអោយលទ្ធផលជាក់ស្តែងនៃការកកើតការងារអភិបាលកិច្ចដែនដី។

ជាការពិតណាស់ គម្រោងផែនការគ្រប់គ្រងដីធ្លីមិនមែនជាផែនការដែលអាចឈរនៅតែឯងក្នុងការធានាអោយមានប្រសិទ្ធភាពដល់ការគ្រប់គ្រងដីធ្លីនោះទេ។ វាត្រូវតែផ្សារភ្ជាប់ទៅនឹងការធ្វើផែនការគ្រប់គ្រងដីធ្លីលំអិតនៅកំរិតថ្នាក់ស្រុក ហើយនិងត្រូវតែធ្វើផែនការគ្រប់គ្រងដីធ្លីកាន់តែលំអិតបន្ថែមទៀតនៅក្នុងកំរិតថ្នាក់ឃុំ។ ប៉ុន្តែសមាហរណកម្មខ្មែរ បណ្តោយដែលកំណត់នូវវិន័យនិងយន្តការសំរាប់ធ្វើការសម្របសម្រួលទៅតាមឋានានុក្រមនោះគឺវាបានបង្ហាញនូវភាពត្រឹមត្រូវ។ ការរៀបចំការបែងចែកអំនាចនិងតួនាទីឡើងវិញដែលត្រូវធ្វើការរៀបចំឡើងវិញរវាងថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ គឺមានភាពស្មុគស្មាញណាស់។ ត្រូវតែធ្វើការស្វែងរកនូវតុល្យភាពរវាងគោលការណ៍នៃការផ្ទេរសិទ្ធអំនាច (ការសំរេចចិត្តគួរតែធ្វើដោយកំរិតថ្នាក់ទាបបំផុតដែលអាចមានលទ្ធភាពធ្វើការងារបាន (Van Acker, 2009, In this Volume) និងតំរូវការដើម្បីការសម្របសម្រួលកត្តាខាងក្រៅដែលជាប់ពាក់ព័ន្ធជាមួយនឹងឥទ្ធិពលនៃសកម្មភាពមូលដ្ឋាន ដែលកើតមានដោយចៃដន្យទៅលើប្រព័ន្ធកសិបរិស្ថានទាំងមូលឬតំបន់ទីជំរាលនៅផ្នែកខាងក្រោម)។ បញ្ហានេះមានភាពស្មុគស្មាញប៉ុន្តែការរៀបចំនៃការដាក់បញ្ចូលគ្នានៃផែនការគ្រប់គ្រងដីធ្លីនៅកំរិតផ្សេងៗគ្នានឹងកាន់តែមានសារៈសំខាន់ថែមទៀតនៅពេល ដែលការផ្ទេរអំនាចត្រូវបានធ្វើឡើងដោយមានការគាំទ្រយ៉ាងពិតប្រាកដពីរាជរដ្ឋាភិបាលប្រទេសកម្ពុជា។ ក្រុមការងារប្លង់គោលខេត្តបាត់ដំបងនឹងមានការពាក់ព័ន្ធក្នុងដំណើរការនេះនាពេលអនាគតដ៏ខ្លីខាងមុខ។

## ៥. សេចក្តីសន្និដ្ឋាន

នៅក្នុងរយៈពេលប្រហែលជាង១៥ឆ្នាំ វិធីសាស្រ្តគ្រប់គ្រងដោយមានការចូលរួមពីសហគមន៍បានក្លាយទៅជាវិធីសាស្រ្តយ៉ាងសំខាន់សំរាប់ធ្វើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោក ២០០៨ ធនាគារពិភពលោកដែលជាស្ថាប័នដ៏មានឥទ្ធិពលមួយ

កំពុងធ្វើការពិចារណាឡើងវិញអំពីតួនាទីរបស់សហគមន៍ដែលអាចដើតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍សហគមន៍ (World Bank, 2007)។ ដូចនេះហើយវាមានការសង្ឃឹមយ៉ាងខ្លាំងថាការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន នឹងនៅតែបន្តការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងពេលអនាគត។

ការងារ និងការរៀបចំនៅថ្នាក់មូលដ្ឋាន គឺជាល័ក្ខខ័ណ្ឌដ៏សំខាន់ដើម្បីឆ្ពោះទៅរកការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ប៉ុន្តែបទពិសោធន៍ពីការងារកន្លងមកបង្ហាញថាការយកចិត្តទុកដាក់ទៅលើសហគមន៍តែមួយជ្រុង គឺទទួលបានផលប្រយោជន៍នៅពេលដែលល័ក្ខខ័ណ្ឌនៅក្នុងមូលដ្ឋានស្ថិតនៅដាច់ដោយឡែកពីបរិបទសេដ្ឋកិច្ចសង្គមនិងកេ្យត្របរិស្ថាន។ ការវិភាគរបស់យើងមិនមែនបដិសេធន៍នូវសារៈសំខាន់របស់អ្នកមូលដ្ឋានក្នុងការចូលរួមចំណែកគាំទ្រដល់សហគមន៍ជនបទនោះទេ ប៉ុន្តែយើងព្យាយាមស្វែងរកនូវវិធីសាស្ត្របន្ថែមទៀត (មិនមែនយកមកជំនួសនោះទេ) ដែលអាចពង្រឹងដល់សហគមន៍ចំពោះការងារចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ។ យើងអះអាងថា ការពិនិត្យទៅលើបរិបទនៃការអភិវឌ្ឍន៍ទាំងមូល ឧ.នៅក្នុងថ្នាក់ខេត្ត គឺវាមានសារៈសំខាន់ណាស់ដើម្បីធ្វើការបង្ហាញផ្លូវដល់កាគ្រប់គ្រងធនធានធម្មជាតិ។ គម្រោងផែនការគ្រប់គ្រងដីធ្លីខេត្តបាត់ដំបងមានផលប្រយោជន៍ជាច្រើនដល់សហគមន៍ពីព្រោះវារួមបញ្ចូលពីការផ្តល់សិទ្ធដល់សហគមន៍ទៅក្នុងទំរង់នៃការប្រើប្រាស់ដីធ្លីក្នុងទំហំមួយធំ។

វាក៏ត្រូវទទួលស្គាល់ថាគ្រប់សហគមន៍ជនបទទាំងអស់គឺជាដៃគូយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍ជនបទ ហើយក៏រួមចំណែកទទួលស្គាល់ដល់ការផ្តល់អំនាចដល់សហគមន៍។ ការកែលំអស្ថានប័នគឺ វាបានពង្រឹងដល់ប្រសិទ្ធភាពវិមជ្ឈការនិងវិសហមជ្ឈការដោយវាមានដំណើរការយ៉ាងច្បាស់លាស់គ្របដណ្តប់បានគ្រប់វិស័យនីមួយៗ។ ដូចនេះវាជាដំណើរការរៀនសូត្រសំរាប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការងារធ្វើផែនការក៏ដូចជានៅក្នុងការត្រួតពិនិត្យ និងវាយតំលៃនៃការធ្វើអោយបានសំរេចដល់ផែនការផងដែរ។

# ឯកសារយោង


CEMAT (2007). *Spatial Development Glossary, Territory and Landscape*. European Conference of Ministers in charge of Regional Planning, Strasbourg, Council of Europe, 75 p.

Council for Land Policy, RGC (2002). *Interim Paper on Strategy of Land Policy Framework*, MLMUPC, Phnom Penh, 40 p.

Council for Land Policy (2005). *Declaration of the Royal Government of Cambodia on the Land Policy.* MLMUPC, Phnom Penh, 5 p.

Diepart, J-C (2007). Recent land dynamics in the Tonle Sap Flood Plain and its impacts on the local communities, *Tonle Sap Biosphere Reserve Bulletin*, Volume 3, Tonle Sap Biosphere Reserve Secretariat, Phnom Penh, pp. 20–22

Diepart J.-C. (2008a). Cambodian peasant's rationality and participation in rural development: a perspective from Kampong Thom Province, *Biotechnology, Agronomy, Society and Environment*, (accepted but not yet published), 25 p.

Diepart, J-C (2008b). *Developing a Spatial Planning Framework for Sustainable Land and Natural Resources Management. A perspective from Battambang Province, Cambodia.* Paper presented at Map Asia 2008, GIS Development, Kula Lumpur, 16 p.

Dupuis, D. (2008). *Evolution récente des régimes fonciers et stratégies de production paysannes. Le Cas de la Province de Battambang, Cambodge.* MSc Thesis (in French). Gembloux Agricultural University, Belgium. 168 p. + annexes

Hobley M. (2007). *Does Forestry have a Role in Poverty Reduction? Issues and Concepts.* Key note address at the International Conference on Poverty Reduction and Forests: Tenure, Market and Policy Reforms. RECOFT, Bangkok

Horng, V. and Craig, D. (2008). *Accountability and Planning in Decentralised Cambodia*. CDRI Working paper Series No. 39, Phnom Penh, 133 p.

IFSR (2004). *Independent Forest Sector Review: the Forest Sector in Cambodia: Part 1. Policy choices, issues and options,* 119 p.

Ken Serey, R. (2005). Understanding the key concept of CBNRM, in Ken Serey, R., Carson, T., Riebe, K., Cox, S. and von Kaschke, E. (2005). *The Development of Community Based Natural Resources Management (CBNRM) in Cambodia.* CBNRM Learning Institute, Phnom Penh, pp. 23–34

Ledgerwood, J. and Vijghen, J. (2002). Decision-Making in Khmer Villages, in Ledgewood, J.(ed). *Cambodia Emerges from the Past: Eight Essays*, Center for Southeast Asian Studies, Northern Illinois University, Southeast Asian publications, DeKalb IL 60115, pp. 117–135

Li, T. (2002). Engaging Simplifications: Community-Based Resource Management, Market Processes and State Agendas in Upland Southeast Asia, *World Development,* Vol. 30, No. 2, London, pp.265–283.

Magel, H. (2008). *Land Management: Spatial Planning and Land Use Planning*. RUA Summer School Key Note address, Phnom Penh, Technical University of Munich, 32 p.

Ostrom E. (1990). *Governing the Commons, the Evolution of Institutions for Collective Action*, Cambridge, Cambridge University Press, 280 p.

Schall, N. (Ed.) (2006). *Sub-provincial Strategic Land Management Development Planning, Planning manual*, GTZ-RGC, Phnom Penh, 34 p.

Regional Planning Committee (2008). *Development and protection plan of key tourism attractions in Battambang province*, Provincial Department of Land Management, Urban Planning, Construction and Cadastre, Battambang, 143 p.

Royal Government of Cambodia (2008). *Law on the Administrative Management of Capital, Provinces, Municipalities, Districts and Khans*

Symann, R. (2008). *Capacity Building in der lokalen Verwaltung am Beispiel Battambang, Kambodscha*, DED Newsletter, Bonn

World Bank (2007). *World Development Report 2008, Agriculture for Development*. World Bank and BIRD, Washington, 386 p.